# ការឃ្លាំមើលរបស់អង្គការមិនមែនរដ្ឋាភិបាលលើគម្រោងស្តារឡើងវិញផ្លូវដែក របស់ប្រទេសកម្ពុជា មានសារសំខាន់ណាស់ចំពោះការអភិវឌ្ឍន៍ ដោយយុត្តិធម៌និងមានការចូលរួម

ថ្ងៃ ទី០៥ ខែកញ្ញា ឆ្នាំ ២០១១

ក្នុងរយៈពេលប៉ុន្មានសប្តាហ៍ថ្មីៗនេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានចាត់វិធានការ ជាបន្តបន្ទាប់ចំពោះអង្គការជាតិ និងអន្តរជាតិមួយចំនួនដែលកំពុងធ្វើការផ្នែកសិទ្ធិមនុស្ស និងតស៊ូមតិ ជាពិសេស អង្គការដែលកំពុងតាមឃ្លាំមើលផលប៉ះពាល់លើការតាំងទីលំនៅថ្មី ពាក់ព័ន្ធនឹងគម្រោងស្តារផ្លូវដែកឡើងវិញ ដែលផ្តល់មូលនិធិដោយធនាគារអភិវឌ្ឍន៍អាស៊ី និងទីភ្នាក់ងារដើម្បីអភិវឌ្ឍន៍ អន្តរជាតិអូស្ត្រាលី។ រាជរដ្ឋាភិបាលកម្ពុជា បានចោទប្រកាន់ជាសាធារណៈចំពោះអង្គការ៤ ដែលមានអង្គការសាមគ្គីអន្តរជាតិគឺ **អង្គការស្ពានទៅកាន់សន្តិភាពកម្ពុជា**, **អង្គការសមាជិកភាព (Umbrella Organization)** និងអង្គការជាតិពីរទៀតគឺ **សមាគមធាងត្នោត** និង**ក្រុមការងារពិសេសសិទ្ធិលំនៅដ្ឋាន**។

អង្គការទាំងនេះបានទទួលរងសម្ពាធយ៉ាងខ្លាំងពីរាជរដ្ឋាភិបាលកម្ពុជា។ ក្រសួងមហាផ្ទៃ បានចេញ លិខិតមួយនៅថ្ងៃទី២ ខែសីហា ដើម្បីផ្អាកដំណើរការរបស់សមាគមធាងត្នោត ចំណែកឯក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិវិញ កាលពីថ្ងៃទី១៨ ខែសីហាកន្លងទៅនេះ បានចេញលិខិតព្រមានមួយច្បាប់ ទៅអង្គការស្ពានទៅកាន់សន្តិភាព និង អង្គការសមាជិកភាព (Umbrella Organization)។ នៅក្នុង លិខិតព្រមាននោះក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិបានបញ្ជាក់ថា អង្គការស្ពានទៅកាន់ សន្តិភាព និង អង្គការសមាជិកភាព (Umbrella Organization)បាន "ចោទប្រកាន់យ៉ាងធ្ងន់ធ្ងរ ... ដែលជាការប៉ុនប៉ង បង្ខូចកិត្តិយសរបស់រាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងដើម្បីញុះញង់ឱ្យសាធារណជនប្រឆាំងរាជរដ្ឋាភិបាល"។ ការចោទប្រកាន់នេះ យោងលើលិខិតមួយច្បាប់ដែលអង្គការមិនមែនរដ្ឋាភិបាល៤បានផ្ញើទៅ លោក ហារូហ៊ីកូ គូរ៉ូដា (Mr. Haruhiko Kuroda) ប្រធានធនាគារអភិវឌ្ឍន៍អាស៊ី កាលពីខែតុលា ឆ្នាំ២០១០ ដែលនៅក្នុង លិខិតនោះបានលើកឡើងពីបញ្ហាមួយចំនួនទាក់ទងនឹងគម្រោងផ្លូវដែក រួមទាំងការស្លាប់ កុមារពីរនាក់នៅឯតំបន់តាំង ទីលំនៅថ្មីនៅខេត្តបាត់តំបង ព្រមទាំងបញ្ហា គ្មានសេវាកម្មមូលដ្ឋាន នៅកំឡុងពេលតាំងទីលំនៅថ្មីនោះ។

ដោយសារបញ្ហានេះ យើងសូមស្រាយបំភ្លឺដូចខាងក្រោម៖

ប្រជាពលរដ្ឋជាច្រើនគ្រួសារត្រូវផ្លាស់ឱ្យទៅនៅទីតាំងថ្មីនៅខេត្តបាត់ដំបង ដែលនៅពេលនោះ គ្មានការផ្គត់ផ្គង់ទឹកស្អាត និងអគ្គិសនីសម្រាប់ប្រើប្រាស់តាមលក្ខខណ្ឌ នៃបទដ្ឋានអប្បបរមានៃការតាំងទីលំនៅថ្មី ដូចមានចែងនៅក្នុងគោលនយោបាយស្ដីពីការតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត។ មិនយូរប៉ុន្មានក្រោយពីបាន ទៅនៅទីតាំងថ្មីនោះ ពួកគាត់បានទៅដងទឹកពីស្រះមួយនៅក្បែរនោះដើម្បីយកមកប្រើប្រាស់ ដែលហេតុ ដូច្នេះហើយទើបមានកុមារពីរនាក់ដែលម្នាក់មានអាយុ៨ឆ្នាំ និងម្នាក់ទៀតមានអាយុ១៣ឆ្នាំបានលង់ទឹក ស្រះនោះស្លាប់គួរឱ្យអាណិតនិងសោកស្ដាយ។ នៅពេលនោះ អង្គការស្ពានទៅកាន់សន្តិភាព បានរៀបចំ ឯកសារអំពីស្ថានភាពនៃព្រឹត្តិការណ៍នោះ និងបានចេញផ្សាយ ឯកសារវីដេអូខ្លីមួយជាសាធារណៈអំពី ហេតុការណ៍នោះ។ ចំណែកឯរបាយការណ៍មួយអំពីរឿងនេះ ដែលផ្សាយដោយទូរទស្សន៍អូស្ត្រាលី (ABC) កាលពីខែឧសភា ឆ្នាំ២០១១ ក៏ជាឯកសារបញ្ជាក់ថែមទៀតជុំវិញបញ្ហាការផ្លាស់ប្ដូរទីលំនៅប្រជាពលរដ្ឋទាំងនោះ។

ឯកសារទាំងពីរនេះ អាចមើលបានតាមគេហទំព័រដូចខាងក្រោមនេះ:

http://www.youtube.com/watch?v=EtFPqcVNlzc&feature=player_embedded និង

http://www.abc.net.au/lateline/content/2011/s3216781.htm

ឯកសារស្រាវជ្រាវប្រកបដោយគុណភាពខ្ពស់ដែលអង្គការទាំងនេះបានរកឃើញគឺជា ភស្តុតាង បង្ហាញអំពីការរំលោភលើគោលនយោបាយសុវត្ថិភាពមួយចំនួន ហើយដែលគេបាននិងកំពុងធ្វើការដើម្បី ដោះស្រាយបញ្ហាដោយសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី និងភ្នាក់ងារដើម្បីអភិវឌ្ឍន៍អន្តរជាតិ អូស្ត្រាលី។ រហូតមកដល់ពេលនេះ និងតទៅមុខ ការងារនេះជាការងារយ៉ាងសំខាន់ ដើម្បីធានាថា គ្រួសារ ប្រជាពលរដ្ឋដែលរងគ្រោះ ទទួលបានការផ្លាស់ប្ដូរទីលំនៅថ្មីនិងសំណងសមរម្យ ព្រមទាំងមានការគាំទ្រ ដល់របរចិញ្ចឹមជីវិត ដែលមិនធ្វើឱ្យពួកគាត់មានជីវភាពធ្លាក់ដុនដាបជាងមុនពេលមាន គម្រោងអភិវឌ្ឍន៍ នេះ ដូចមានចែងនៅ ក្នុងគោលនយោបាយតាំងទីលំនៅថ្មីដោយមិនស្ម័គ្រចិត្តរបស់ធនាគារ អភិវឌ្ឍន៍អាស៊ី។ ដូចបានលើកឡើង នៅក្នុងសេចក្ដីថ្លែងការណ៍ជាសាធារណៈកាលពីថ្ងៃទី១៨ ខែសីហា ដែល ធនាគារ អភិវឌ្ឍន៍អាស៊ីបញ្ជាក់ថា "*ធនាគារជឿថា អង្គការមិនមែនរដ្ឋាភិបាលនិងសង្គមស៊ីវិលដើរតួនាទី យ៉ាងសំខាន់ក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍នេះដោយជោគជ័យ ព្រមទាំងសង្ឃឹមថាអង្គការមិនមែន រដ្ឋាភិបាលនឹងត្រូវអនុញ្ញាតឱ្យបន្តធ្វើការ លើគម្រោងអភិវឌ្ឍន៍ផ្លូវដែកនេះបន្តទៀត*"។

សមាគមធាងត្នោត អង្គការស្ពានទៅកាន់សន្តិភាពកម្ពុជា ក្រុមការងារពិសេសសិទ្ធិលំនៅដ្ឋាន និងអង្គការសមាជិកភាព (Umbrella Organization) បាន និងកំពុងធ្វើការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី និងភ្នាក់ងារដើម្បីអភិវឌ្ឍន៍អន្តរជាតិអូស្ត្រាលី ដើម្បីឆ្ពោះទៅ រកការដោះស្រាយបញ្ហាមួយ ចំនួនទាក់ទង នឹង គម្រោង

នេះ ដើម្បីធានាថា ការអនុវត្តគម្រោងទទួលបាន ជោគជ័យ ដែលទន្ទឹមគ្នានេះដែរក៏ព្យាយាមធ្វើឱ្យ សុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ដែលប្រឈមនឹងផលប៉ះពាល់ដោយការអនុវត្តគម្រោង បានល្អ ប្រសើរ និងដើម្បីឱ្យពួកគាត់ទទួលបានសិទ្ធិមានជីវភាពរស់នៅសមរម្យ យ៉ាងពេលលេញ។ ប្រជាពលរដ្ឋប៉ះពាល់ នៅតាមបណ្តោយផ្លូវរថភ្លើងកំពុងមានការភ័យខ្លាចកាន់តែខ្លាំងឡើង១ ព្រមទាំងបារម្ភ ថា ប្រសិនបើ គ្មានការឃ្លាំមើលការអនុវត្តគម្រោងនេះ ដោយអង្គការមិនមែនរដ្ឋាភិបាលទេ ដូច្នេះ ការរំលោភលើគោលនយោ បាយសុវត្ថិភាព នៅតែបន្តមិនអាចដោះស្រាយបានដដែល ។

ការផ្អាកដំណើរការរបស់សមាគមធាងត្នោត និងការព្រមានជាសាធារណៈដល់អង្គការស្ពានទៅកាន់ សន្តិភាព កម្ពុជា និង អង្គការសមាជិកភាព (Umbrella Organization) អាចនាំអោយមានផលប៉ះពាល់អវិជ្ជមាន លើគម្រោងនេះ។

សូមបញ្ជាក់ថាអង្គការទាំងអស់មិនបានប្រឆាំងទៅនឹងគម្រោងស្តារផ្លូវដែកឡើងវិញនោះទេ។ អង្គការទាំង អស់សូមគាំទ្រទាំងស្រុងចំពោះគម្រោងអភិវឌ្ឍដែលកាត់បន្ថយភាពក្រីក្រ និង លើកកម្ពស់សិទ្ធិរបស់ប្រជា ពលរដ្ឋរួមទាំងសិទ្ធិទទួលបានជីវភាពរស់នៅសមរម្យ ។

យើងខ្ញុំសូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា ធនាគារអភិវឌ្ឍន៍អាស៊ី និងភ្នាក់ងារដើម្បីអភិវឌ្ឍន៍អន្តរជាតិ អូស្ត្រាលី សូមអនុវត្តគម្រោង និងគោលនយោបាយរបស់ខ្លួន រួមទាំងគោលនយោបាយតាំងទីលំនៅថ្មីដោយ មិនស្ម័គ្រចិត្ត ឱ្យបានពេលលេញ។ ទន្ទឹមគ្នានេះដែរ យើងខ្ញុំ សប្បាយចិត្តនឹងផ្តល់ជំនួយដែលយើងខ្ញុំអាចធ្វើបាន ដើម្បីសម្រេចគោលដៅនេះ។

ទំនាក់ទំនង:

លោក សៀភិរម្យ ទូរសព្ទ័ ០១២ ៨៩២ ៣២៥

លោកអៀង វុទ្ធី  ទូរសព្ទ័ ០១២ ៧៩១ ៧00

អ្នកស្រី Naly Pilorge,  ទូរសព្ទ័ ០១២ ៨0៣ ៦៥0